**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និង កីឡា**
**លេខ : ០៧ អយក.សរណន**

# សារាចរណែនាំ
## ស្តីពី
## លក្ខខណ្ឌនៃការទទួលស្គាល់បញ្ជីឈ្មោះនិស្សិត មធ្យមសិក្សាបច្ចេកទេស ឬ ឯកទេស ឬ ថ្នាក់បរិញ្ញាបត្ររង និង ថ្នាក់បរិញ្ញាបត្រ ដែលកំពុងសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សា

**យោង :** -ប្រកាសលេខ ៦៤១ អយក.ប្រក ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០០ របស់ក្រសួងអប់រំ យុវជន និង កីឡា ស្តីពីបទបញ្ជាក្នុងការចុះឈ្មោះចូលរៀន នៅក្នុងគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និង ឯកជន

-ប្រកាសលេខ ៤៥០ អយក.ប្រក ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០២ របស់ក្រសួងអប់រំ យុវជន និង កីឡា ស្តីពីបទបញ្ជាជ្រើសរើសនិស្សិតអោយចូលរៀន នៅក្នុងគ្រឹះស្ថានឧត្តមសិក្សា

-សារាចរណែនាំលេខ ០៦ អយក.សរណន ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០០២ របស់ក្រសួងអប់រំ យុវជន និង កីឡា ស្តីពីការបើកឯកទេសថ្មី ដេប៉ាតឺម៉ង់ថ្មី មហាវិទ្យាល័យថ្មី ថ្នាក់ថ្មី និង ការបើកសាខានៅតាមគ្រឹះស្ថានឧត្តមសិក្សា

កន្លងមកក្រសួងអប់រំ យុវជន និង កីឡា បានកត់សំគាល់ឃើញថា គ្រឹះស្ថានឧត្តមសិក្សាមួយចំនួន ក្រោយពីការប្រលង និង ជ្រើសរើសនិស្សិតថ្មីអោយចូលរៀន បានរូសរាន់បញ្ជូនបញ្ជីឈ្មោះនិស្សិតមកក្រសួងដើម្បីសុំការទទួលស្គាល់ ប៉ុន្តែក៏មានគ្រឹះស្ថានឧត្តមសិក្សាមួយចំនួនទៀតពុំបានយកចិត្តទុកដាក់លើបញ្ហានេះ ហើយពន្យារហួតដល់ចប់ឆ្នាំសិក្សាទើបបញ្ជូនបញ្ជីឈ្មោះនិស្សិតមកក្រសួង ដើម្បីសុំការទទួលស្គាល់ ។ ដើម្បីពង្រឹងការងារនេះ ក្រសួងអប់រំ យុវជន និង កីឡា សូមធ្វើការណែនាំដូចខាងក្រោម :

**I-សំណុំបែបបទស្នើសុំត្រូវមាន :**

**ក-សំរាប់ថ្នាក់ឆ្នាំទី១**

១-លិខិតផ្សព្វផ្សាយដំណឹងប្រលង រឺ ជ្រើសរើសដែលក្នុងនោះមានកំនត់នូវលក្ខខណ្ឌ នៃការចុះឈ្មោះប្រលង រឺ ជ្រើសរើសអោយចូលរៀន វិញ្ញាសាប្រលង មុខវិជ្ជាដែលជ្រើសរើស និទ្ទេសតាមមុខវិជ្ជា និង និទ្ទេសសរុប

Re.Instistu

២-បញ្ជីឈ្មោះបេក្ខជនប្រលងវី ជ្រើសរើស

៣-បញ្ជីវត្តមានបេក្ខជនដែលបានមកប្រលង

៤-គណៈកម្មការប្រលងនានាដែលក្រសួងអប់រំ យុវជន និង កីឡា បានទទួលស្គាល់

៥-បញ្ជីឈ្មោះបេក្ខជនដែលបានប្រលងជាប់វី ជ្រើសរើសជាប់សំរេចដោយគណៈកម្មការប្រលងវី ជ្រើសរើស

៦-របាយការណ៍ស្តីពីការប្រលងវី ជ្រើសរើស

៧-បញ្ជីឈ្មោះនិស្សិតរៀននៅថ្នាក់ឆ្នាំទី១ ដែលត្រូវស្នើសុំអោយក្រសួងអប់រំ យុវជន និង កីឡាទទួលស្គាល់

៨-ក្នុងករណីនៅក្នុងបញ្ជីឈ្មោះនិស្សិតរៀននៅថ្នាក់ឆ្នាំទី១ ដែលត្រូវស្នើសុំក្រសួងអប់រំ យុវជន និង កីឡា ទទួលស្គាល់មានឈ្មោះនិស្សិតខុសពីបញ្ជីឈ្មោះបេក្ខជនដែលបានប្រលងជាប់វី ជ្រើសរើសជាប់នោះគ្រឹះស្ថានសិក្សាត្រូវភ្ជាប់មកជាមួយបន្ថែមនូវឯកសារដែលពាក់ព័ន្ធទៅ នឹងនិស្សិតទាំងនោះ

៩-ពាក្យស្នើសុំអោយក្រសួងអប់រំ យុវជន និង កីឡា ទទួលស្គាល់បញ្ជីឈ្មោះនិស្សិតរៀននៅថ្នាក់ឆ្នាំទី១

**ខ-<u>សំរាប់និស្សិតថ្នាក់ឆ្នាំទី២</u> :**

១-ពាក្យស្នើសុំទទួលស្គាល់

២-សេចក្តីសំរេចរបស់ក្រុមប្រឹក្សាបច្ចេកទេសដែលសំរេចអោយនិស្សិតឆ្នាំទី១បានជាប់ឡើងថ្នាក់ឆ្នាំទី២ មុខជំនាញដដែល

៣-បញ្ជីឈ្មោះនិស្សិតដែលកំពុងរៀននៅថ្នាក់ឆ្នាំទី២ តាមមុខជំនាញ ដែលត្រូវស្នើសុំអោយក្រសួងអប់រំ យុវជន និង កីឡា ទទួលស្គាល់

៤-ក្នុងករណីមានឈ្មោះនិស្សិតនៅក្នុងបញ្ជីឈ្មោះនិស្សិតថ្នាក់ឆ្នាំទី២ ខុសពីនៅក្នុងបញ្ជីឈ្មោះនិស្សិតថ្នាក់ឆ្នាំទី១ នាឆ្នាំកន្លងមកដែលត្រូវបានឡើងថ្នាក់សំរេចដោយក្រុមប្រឹក្សាបច្ចេកទេសនោះត្រូវភ្ជាប់មកជាមួយបន្ថែមនូវឯកសារដែលពាក់ព័ន្ធទៅនឹងនិស្សិតទាំងនោះ ។

**គ-<u>សំរាប់និស្សិតថ្នាក់ឆ្នាំទី៣</u> :**

១-ពាក្យស្នើសុំទទួលស្គាល់

២-សេចក្តីសំរេច របស់ក្រុមប្រឹក្សាបច្ចេកទេស ដែលសំរេចអោយនិស្សិតឆ្នាំទី២ បានជាប់ឡើងថ្នាក់ឆ្នាំទី៣ មុខជំនាញដដែល

៣-បញ្ជីឈ្មោះនិស្សិតដែលកំពុងរៀននៅថ្នាក់ឆ្នាំទី៣ តាមមុខជំនាញដែលត្រូវស្នើសុំអោយក្រសួងអប់រំ យុវជន និង កីឡា ទទួលស្គាល់

៤-ក្នុងករណីមានឈ្មោះនិស្សិត នៅក្នុងបញ្ជីឈ្មោះនិស្សិតថ្នាក់ឆ្នាំទី៣ ខុសពីនៅក្នុងបញ្ជីឈ្មោះនិស្សិតថ្នាក់ឆ្នាំទី២ នាឆ្នាំកន្លងមក ដែលត្រូវបានឡើងថ្នាក់សំរេចដោយក្រុមប្រឹក្សាបច្ចេកទេសនោះ ត្រូវភ្ជាប់មកជាមួយបន្ថែមនូវឯកសារដែលពាក់ព័ន្ធ ទៅនឹងនិស្សិតទាំងនោះ ។

**ឃ-សំរាប់និស្សិតថ្នាក់ឆ្នាំទី៤ :**

១-ពាក្យស្នើសុំទទួលស្គាល់

២-សេចក្តីសំរេច របស់ក្រុមប្រឹក្សាបច្ចេកទេស ដែលសំរេចអោយនិស្សិតឆ្នាំទី៣ បានជាប់ឡើងថ្នាក់ឆ្នាំទី៤ មុខជំនាញដដែល

៣-បញ្ជីឈ្មោះនិស្សិតដែលកំពុងរៀននៅថ្នាក់ឆ្នាំទី៤ តាមមុខជំនាញដែលត្រូវស្នើសុំអោយក្រសួងអប់រំ យុវជន និង កីឡា ទទួលស្គាល់

៤-ក្នុងករណីមានឈ្មោះនិស្សិតនៅក្នុងបញ្ជីឈ្មោះនិស្សិតថ្នាក់ឆ្នាំទី៤ ខុសពីនៅក្នុងបញ្ជីឈ្មោះនិស្សិតថ្នាក់ឆ្នាំទី៣ នាឆ្នាំកន្លងមក ដែលត្រូវបានឡើងថ្នាក់សំរេចដោយក្រុមប្រឹក្សាបច្ចេកទេសនោះ ត្រូវភ្ជាប់មកជាមួយបន្ថែមនូវឯកសារដែលពាក់ព័ន្ធទៅនឹងនិស្សិតទាំងនោះ

## II-**កាលបរិច្ឆេទបញ្ជូនសំណុំបែបបទ និង ការទទួលស្គាល់**

គ្រឹះស្ថានសិក្សាត្រូវបញ្ជូន សំណុំបែបបទរបស់និស្សិតរៀននៅថ្នាក់ឆ្នាំទី១ អោយមកដល់នាយកដ្ឋានឧត្តមសិក្សានៅ ក្រោយការប្រលងវិជ្រើសរើសចំនួន ២៥ថ្ងៃ ដើម្បីសុំការទទួលស្គាល់ ។ ក្នុងករណីបញ្ជូនមកក្រោយការកំណត់នេះ ក្រសួងអប់រំ យុវជន និង កីឡា នឹងមិនទទួលស្គាល់បញ្ជីឈ្មោះនិស្សិតទាំងនោះឡើយ ។ ចំពោះសំណុំបែបបទរបស់និស្សិតថ្នាក់ឆ្នាំទី២ ទី៣ ទី៤ និង ថ្នាក់ឆ្នាំបន្តបន្ទាប់ គ្រឹះស្ថានសិក្សាត្រូវបញ្ជូនមកដល់នាយកដ្ឋានឧត្តមសិក្សា នៅក្រោយការចូលរៀនចំនួន ២០ថ្ងៃ ដើម្បីសុំការទទួលស្គាល់ ។ ក្នុងករណីបញ្ជូនមកក្រោយថ្ងៃកំនត់នេះ ក្រសួងអប់រំ យុវជន និង កីឡា នឹងមិនទទួលស្គាល់បញ្ជីឈ្មោះនិស្សិតទាំងនោះឡើយ ។

គ្រឹះស្ថានឧត្តមសិក្សាណា ដែលបានបំពេញគ្រប់គ្រាន់តាមលក្ខខណ្ឌខាងលើ នោះក្រសួងអប់រំ យុវជន និង កីឡា និង ចេញសេចក្តីបញ្ជាក់ទទួលស្គាល់លើបញ្ជីឈ្មោះនិស្សិតទាំងនោះ ។

បន្ទាប់ពីបានទទួលសារាចរណែនាំនេះគ្រឹះស្ថានឧត្តមសិក្សានីមួយៗត្រូវអនុវត្តអោយបានត្រឹមត្រូវ ដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

ភ្នំពេញ ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៣

**ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

**រដ្ឋលេខាធិការ**

**អ៊ឹម សិទ្ធី**

**កន្លែងទទួល :**

-ទីស្តីការគណៈរដ្ឋមន្ត្រី

" ដើម្បីសូមជ្រាបជាពតិមាន "

-អគ.ឧបវ-អគ.រហ

-ន.រដ្ឋបាល-ន.បុគ្គលិក

-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក

" ដើម្បីជ្រាបជាពត៌មាន "

-គ្រប់គ្រឹះស្ថានឧត្តមសិក្សាក្រោមឱវាទ

" ដើម្បីអនុវត្ត "

-កាលប្បវត្តិ

Re.Instistu